# អនុក្រឹត្យ លេខ ០៧ អនក្រ.បក
# ស្តីពី
# ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តតាកែវ ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទ ជាលក្ខណៈគ្រួសារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តតាកែវ ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទ លេខ ២ . ៣. ៤ .៦ . ៧. ៨. ៩. ១០. ១៣. ១៧ និងលេខ ១៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តតាកែវ និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកណ្ដាល ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា ( ហិកតា)

| ឈ្មោះខេត្ត និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| [illegible] | | | | | |
| ១ | ២ ៨៣៦ | ២៤ | ២ ៨១២ | ០.៨ | |
| ២ | ១ ៧៣៣ | ១ ៧៣៣ | ០ | ១០០ | លុបចោល |
| ៣ | ៩៥១ | ៩៥១ | ០ | ១០០ | លុបចោល |
| ៤ | ២ ១០៥ | ២ ១០៥ | ០ | ១០០ | លុបចោល |
| ៥ | ៣៩៤ | ០ | ៣៩៤ | ០ | |
| ៦ | ១ ២២៣ | ១ ២២៣ | ០ | ១០០ | លុបចោល |
| ៧ | ១ ១៤៨ | ១ ១៤៨ | ០ | ១០០ | លុបចោល |
| ៨ | ៦៣០ | ៦៣០ | ០ | ១០០ | លុបចោល |
| ៩ | ១ ២២១ | ១ ២២១ | ០ | ១០០ | លុបចោល |
| ១០ | ១ ៧៦០ | ១ ៧៦០ | ០ | ១០០ | លុបចោល |
| ១១ | ១ ៣៦៥ | ០ | ១ ៣៦៥ | ០ | |
| ១២ | ៩០២ | ០ | ៩០២ | ០ | |
| ១៣ | ៣ ៩២២ | ៣ ៩២២ | ០ | ១០០ | លុបចោល |
| ១៤ | ៧ ៥៧៤ | ២ ៤៦១ | ៥ ១១៣ | ៣២ ៤៩ | |
| ១៥ | ២ ៦៣៦ | ០ | ២ ៦៣៦ | ០ | |
| ១៦ | ២ ០៨៣ | ១ ០២៣ | ១ ០៦០ | ៤៩ ១១ | |
| ១៧ | ១ ៨៥៧ | ១ ៨៥៧ | ០ | ១០០ | លុបចោល |

| | | | | | |
|---|---|---|---|---|---|
| ១៨ | ៩១៩ | ០ | ៩១៩ | ០ | |
| ១៩ | ៤ ០៧៥ | ៤ ០៧៥ | ០ | ១០០ | លុបចោល |
| ២០ | ៦ ៦៧៣ | ១ ៩០៨ | ៤ ៧៦៥ | ២៨ ៥៩ | |
| សរុប ២០ | ៤៦ ០០៧ | ២៦ ០៤១ | ១៩ ៩៦៦ | ៥៦ ៦០ | |

**មាត្រា ២ .-**

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុមហែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្ដាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**